**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...៤៧៤.........ស.ន.ប

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារ នៃវិស័យសុខាភិបាល ជូនការិយាល័យច្រកចេញចូលតែមួយនៅស្រុកបទេល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

-បានឃើញប្រកាសលេខ ០០១៨ អបស/ឱអបស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ស្តីពីបែបបទ និងលក្ខខណ្ឌ ក្នុងការសុំបើកឬបិទ ឬសុំប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ

-បានឃើញប្រកាសលេខ ០៣៨ អបស/អពចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការកែសម្រួលបែបបទនិងលក្ខខណ្ឌបច្ចេកទេសក្នុងការសុំបើកឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រឯកជន

-បានឃើញប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខ័ណ្ឌគោលដៅរបស់ក្រសួងមហាផ្ទៃ

-បានឃើញសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ សាកល្បងនៅស្រុកសៀមរាប ស្រុកបាត់ដំបង ខេត្តបាត់ដំបង

-បានឃើញសេចក្តីសម្រេចលេខ ១៣២៩សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុងគោលដៅ នៃគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទីពីរ (២០១០-២០១១)

-បានឃើញលិខិតលេខ ៦៤ អ.វ.ម ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយមានចំណារ ឯកភាពរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរឈ្មោះ ស្រុក ខណ្ឌគោលដៅ នៃគំរោងការិយាល័យច្រកចេញចូលតែមួយ

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨២៦ ០៣៤ / ៨៨៤ ៩០៩ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

**សម្រេច**

**ប្រការ១**.-

ត្រូវបានធ្វើប្រតិភូកម្មមុខងារ ពីក្រសួងសុខាភិបាល ជូនដល់ការិយាល័យច្រកចេញចូលតែមួយនៅស្រុកបវេល ក្នុងការចេញលិខិតអនុញ្ញាត សុំបើក ឬ បិទ ឬប្តូរទីតាំង និងបន្តសុពលភាពសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

**ប្រការ២**.-

ការិយាល័យច្រកចេញចូលតែមួយ នៅស្រុកបវេល ត្រូវទទួលមុខងារ ក្នុងការចេញលិខិតអនុញ្ញាត ដូចចែងក្នុងប្រការ ១ខាងលើ ។

**ប្រការ ៣**.-

សេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលត្រូវធ្វើប្រតិភូកម្មជូនការិយាល័យច្រកចេញចូលតែមួយ នៅស្រុកបវេល ក្នុងការចេញលិខិតអនុញ្ញាត មាន:

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុននិងក្រោយសម្រាល គ្រប់គ្រងដោយឆ្មប ដែលមានកំរិតបរិញ្ញាបត្ររងឆ្មប ឬសញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ព្យាបាលដោយចលនា គ្រប់គ្រងដោយអ្នកព្យាបាលដោយចលនា ដែលមានកម្រិត បរិញ្ញាបត្ររងព្យាបាលដោយចលនា ឬសញ្ញាបត្រសមមូលឡើងទៅទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ថែទាំជំងឺ គ្រប់គ្រងដោយគិលានុបដ្ឋាក ដែលមានកម្រិត បរិញ្ញាបត្ររងគិលានុបដ្ឋាក ឬសញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-ឱសថស្ថានរង គ្រប់គ្រងដោយ ឱសថការីមធ្យម ដែលមានសញ្ញាបត្រ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

**ប្រការ៤**.-

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវរៀបចំគម្រូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធសម្រាប់ការចេញលិខិតអនុញ្ញាតទៅតាមប្រភេទសេវាសុខាភិបាលដូចចែងក្នុងប្រការ៣ ។

**ប្រការ៥**.-

ការអនុញ្ញាតលើគម្រូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត របស់ការិយាល័យច្រកចេញចូលតែមួយ នៅស្រុកបវេល របស់មន្ត្រីជំនួយការ អភិបាលស្រុកបវេល ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងសុខាភិបាល ។

**ប្រការ៦**.-

សាលាស្រុកបវេល មានការិយាល័យច្រកចេញចូលតែមួយ ត្រូវធ្វើលិខិតចម្លង ស្តីពីការផ្តល់លិខិតអនុញ្ញាត ដូចចែងក្នុងប្រការ១ខាងលើ និងផ្តល់របាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ មកក្រសួងសុខាបាលតាមរយ:មន្ទីរសុខាភិបាលខេត្តបាត់ដំបង ។

**ប្រការ៧**.-

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-សាលាខេត្តពាក់ព័ន្ធ
-ដូចប្រការ ៧
-ឯកសារ-កាលប្បវត្តិ

មំ ប៊ុនហេង